NSW GOVERNMENT | Education

Parent online payments

# ការបង់ប្រាក់តាមអ៊ីនធើណិតសម្រាប់មាតាបិតា

## ព័ត៌មានសម្រាប់មាតាបិតា និងអ្នកថែទាំ

ឥឡូវនេះ មាតាបិតាអាចបង់ប្រាក់បានតាមអ៊ីនធើណិតទៅឱ្យសាលារៀន សម្រាប់ចំនួនទឹកប្រាក់ដែលសិស្សជំពាក់តាមរយៈទំព័របង់ប្រាក់ដោយសុវត្ថិភាពដែលរៀបចំឡើងដោយ Westpac។ ការបង់ប្រាក់អាចធ្វើបានដោយប្រើប័ណ្ណឥណទាន ឬប័ណ្ណឥណពន្ធ Visa ឬ MasterCard ហើយអាចធ្វើឡើងតាមរយៈខុមព្យូធើរ ខុមព្យូធើរបន្ទះ (tablet) ឬទូរស័ព្ទដៃ។ ទំព័របង់ប្រាក់អាចចូលដំណើរការបានពីទំព័រដើមនៃវ៉ិបសៃរបស់សាលា ដោយជ្រើសរើសយក $ Make a payment ($ ដើម្បីបង់ប្រាក់)។

Westpac ក្នុងពេលថ្មីៗនេះបានកែលម្អប្រព័ន្ធបង់ប្រាក់ គឺអនុញ្ញាតឱ្យមាតាបិតាមានពេលវេលាបន្ថែមទៀតដើម្បីវាយបញ្ចូលព័ត៌មានលម្អិតបង់ប្រាក់ដោយប្រើជម្រើសបំពេញស្វ័យប្រវត្តិ ដូច្នេះដោយមិនចាំបាច់វាយបញ្ចូលព័ត៌មានលម្អិតរបស់ពួកគេម្តងទៀតទេ។ ឥឡូវនេះ មាតាបិតាអាចបង់ប្រាក់បានតាមរយៈប័ណ្ណឥណទាន ឬដកចេញផ្ទាល់ពីគណនីធនាគារ។

មុខវត្ថុដែលអាចបង់បានរួមមានប្រាក់វិភាគទានសាលាដោយស្ម័គ្រចិត្ត ប្រាក់វិភាគទានសម្រាប់មុខវិជ្ជា ដំណើរសិក្សាសាលា វត្ថុដែលលក់ទៅឱ្យសិស្ស និងសកម្មភាពសិល្បៈច្នៃប្រឌិត និងសិល្បៈអនុវត្ត (រួមមានក្រុមតន្ត្រី ល្ខោន និងរបាំ)។ ក៏មានប្រភេទមួយផ្សេងទៀតដែរហៅថា 'ផ្សេងទៀត' ដែលមិនគ្របដណ្តប់នៅក្នុងចំណងជើង 'ផ្សេងទៀត' ពីមុន អាចយកប្រើបានដើម្បីបង់ប្រាក់ពេញលេញនៃរបាយការណ៍គណនីរបស់សាលា។

នៅពេលលោកអ្នកចូលដំណើរការ $ Make a payment លោកអ្នកត្រូវវាយបញ្ចូល៖

ឈ្មោះសិស្ស

ថ្នាក់រៀន

ថ្ងៃខែឆ្នាំកំណើត

ព័ត៌មានលម្អិតទាំងនេះត្រូវបានវាយបញ្ចូលរៀងរាល់ពេលដែលលោកអ្នកបង់ប្រាក់ ដ្បិតអីសាលារៀនមិនរក្សាទុកព័ត៌មានរបស់សិស្សក្នុងប្រព័ន្ធបង់ប្រាក់ទេ។

នេះគឺជាប្រព័ន្ធបង់ប្រាក់ដែលមានសុវត្ថិភាព ដែលចាត់ចែងឡើងដោយ Westpac ដើម្បីធានាថាព័ត៌មានអំពីប័ណ្ណឥណទាន ឬប័ណ្ណឥណពន្ធរបស់លោកអ្នក ត្រូវបានវាយបញ្ចូលដោយលក្ខណៈសុវត្ថិភាព។ ព័ត៌មានលម្អិតទាំងនេះមិនត្រូវបានបញ្ជូនត្រឡប់ទៅឱ្យសាលារៀនវិញទេ។

លោកអ្នកមានសមត្ថភាពដើម្បីពិនិត្យ និងផ្លាស់ប្តូរព័ត៌មានលម្អិតនៃការបង់ប្រាក់ មុនពេលដំណើរការបង់ប្រាក់ត្រូវបានចាត់ចែង។ វិក្កយប័ត្រអាចធ្វើតាមអ៊ីម៉ែល និង/ឬបោះពុម្ព។

ព័ត៌មានលម្អិតអំពីការបង់ប្រាក់ត្រូវបានបញ្ជូនទៅសាលារៀនជារៀងរាល់ថ្ងៃ ដែលសាលារៀននឹងទូទាត់ជាមួយនឹងគណនីរបស់កូនលោកអ្នក។ ដោយព្រោះថាវិក្កយប័ត្រត្រូវបានចេញជូនលោកអ្នកពីទំព័របង់ប្រាក់ ដូច្នោះសាលារៀននឹងមិនចេញវិក្កយប័ត្រជូនលោកអ្នកម្តងទៀតទេ។

សម្រាប់ការសាកសួរណាមួយទាក់ទិននឹងដំណើរការបង់ប្រាក់តាមអ៊ីនធើណិត សូមទំនាក់ទំនងការិយាល័យរដ្ឋបាលសាលា។

## សេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើលោកអ្នកត្រូវការជំនួយភាសាអង់គ្លេសដើម្បីទាក់ទងជាមួយសាលារៀន សូមទូរស័ព្ទទៅសេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទលេខ 131 450 សូមប្រាប់ពួកគេពីភាសាដែលលោកអ្នកត្រូវការ ហើយស្នើសុំឱ្យប្រតិបត្តិករទូរស័ព្ទទៅសាលារៀន។ ប្រតិបត្តិករនឹងរៀបចំអ្នកបកប្រែភាសាតាមទូរស័ព្ទ ដើម្បីជួយលោកអ្នកនៅក្នុងការសន្ទនា។ លោកអ្នកនឹងមិនត្រូវបានគេគិតប្រាក់ចំពោះសេវាកម្មនេះទេ។